**ធនាគារ ព្រីនស៍ ម.ក**

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីបញ្ចុះតម្លៃជាមួយ Agoda

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីបញ្ចុះតម្លៃជាមួយ Agoda តាមរយៈការកក់បញ្ជាទិញការស្នាក់នៅ តាមរយៈគេហទំព័រAgoda ដោយប្រើប្រាស់ប័ណ្ណ ធនាគារ ព្រីនស៍ (UPI MasterCard Visa) ជាមធ្យោបាយទូទាត់ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អតិថិជន យល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ បញ្ញត្តិ និងលក្ខខណ្ឌរបស់ Agoda និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀតៈ

១. រាល់អតិថិជនចាស់ និងអតិថិជនថ្មីជារូបវន្តបុគ្គលរបស់ ធនាគារ ព្រីនស៍ ដែលប្រើប្រាស់ប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ ប្រភេទណាមួយ (UPI MasterCard ឬ Vsia) ដែលចេញដោយ ធនាគារ ព្រីនស៍ រួមទាំងម្ចាស់ប័ណ្ណមេ ឬម្ចាស់ប័ណ្ណរង ("**អ្នកចូលរួម**") អាចចូលរួមកម្មវិធីលើកទឹកចិត្តនេះបាន។

២. អតិថិជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម នឹងទទួលរង្វាន់លើកទឹកចិត្ត ("**រង្វាន់លើកទឹកចិត្ត**") ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម។

| ប្រភេទប្រតិបត្តិការ | រង្វាន់លើកទឹកចិត្ត (ការបញ្ចុះតម្លៃ) | លក្ខខណ្ឌ | រយៈពេលកម្មវិធីលើកទឹកចិត្ត |
|---|---|---|---|
| ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើប្រាស់ប័ណ្ណ ធនាគារ ព្រីនស៍ ដូចជាប័ណ្ណ UPI MasterCard និង Visa (ទាំងប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន) | បញ្ចុះតម្លៃ៦% * | - បញ្ជាទិញតាម https://www.agoda.com/princebank<br>- អនុវត្តចំពោះការស្នាក់នៅដែលមានសម្គាល់ "Promo Eligible" ប៉ុណ្ណោះ<br>- រយៈពេលស្នាក់នៅៈ ថ្ងៃទី០១ មករា ២០២៤ រហូតដល់ ៣១ មីនា ២០២៥ | ០១ មករា ដល់ ៣១ ធ្នូ ២០២៤ |

(*សម្គាល់ៈ ការបញ្ចុះតម្លៃ អនុវត្តចំពោះថ្លៃស្នាក់នៅប៉ុណ្ណោះ និងមិនរួមបញ្ចូលពន្ធ កម្រៃសេវាកម្ម កម្រៃសេវាដំណើរការ ចំណាយផ្ទាល់ខ្លួន និងចំណាយប្រហាក់ប្រហែលឡើយ។)

៣. រង្វាន់លើកទឹកចិត្តជាការបញ្ចុះតម្លៃ នឹងត្រូវបានផ្តល់ជូនអ្នកចូលរួមភ្លាមៗនៅពេលបញ្ជាទិញ ដោយអនុលោមតាម បញ្ញត្តិ និងលក្ខខណ្ឌនេះ នៅក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ឬរហូតដល់ពេលដែលគម្រោងថវិការដែលត្រូវបានអនុម័តសម្រាប់កម្មវិធីលើកទឹកចិត្តនេះ ត្រូវបានចំណាយអស់។

៤. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬ

ដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អ្នកចូលរួម យល់ព្រមដោយមិនដកវិញថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៥. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់មកវិញជូនធនាគារ ព្រីនស៍ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពីធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៦. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬរង្វាន់លើកទឹកចិត្ត នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្តដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ធនាគារ ព្រីនស៍។

៧. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។